ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា
លេខ:.....០០១..........គ.ល.ក.សលាន

ថ្ងៃចន្ទ ១០ កើត ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ២០២៤

# សេចក្ដីណែនាំ
## ស្ដីពី
## ការពង្រឹងការគ្រប់គ្រងប្រតិបត្តិការល្បែងផ្សងសំណាងនៅក្នុងព្រះរាជាណាចក្រកម្ពុជា

**យោង៖** - ព្រះរាជក្រមលេខ នស/រកម/១១២០/០៣១ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម

- ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៨ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្ក្រាបល្បែងស៊ីសង។

កន្លងមក គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា (**គ.ល.ក.**) បានសង្កេតឃើញថា នៅតាមមូលដ្ឋានរាជធានី-ខេត្តមួយចំនួន មានការលួចលាក់ធ្វើអាជីវកម្មល្បែងផ្សងសំណាងនៅលើទីតាំងដែលគ្មានអាជ្ញាបណ្ណល្បែងផ្សងសំណាង និង/ឬអាជ្ញាបណ្ណសាខាល្បែងផ្សងសំណាង និង/ឬលិខិតអនុញ្ញាតប៉ុស្តិ៍សេវាល្បែងផ្សងសំណាងពី **គ.ល.ក.** និងការលួចលាក់បង្កប់ល្បែងស៊ីសងខុសច្បាប់ រួមមាន៖ ឆ្នោតកន្ទុយលេខ ខេណូ (KENO) និងល្បែងស៊ីសងខុសច្បាប់ដទៃទៀត ដែលធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សណ្ដាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងគោលនយោបាយភូមិ-ឃុំសង្កាត់ មានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល។ ក្នុងគោលបំណងធានាបាននូវនិរន្តរភាពនៃការគ្រប់គ្រង រក្សាបាននូវសណ្ដាប់ធ្នាប់សាធារណៈ និងសីលធម៌សង្គមឱ្យបានល្អប្រសើរ និងដើម្បីគ្រប់គ្រងអាជីវកម្មល្បែង-ផ្សងសំណាងឱ្យស្របទៅតាមច្បាប់ គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា ដាក់ចេញសេចក្ដីណែនាំដូចខាងក្រោម៖

**១. ចំពោះអ្នកកាន់អាជ្ញាបណ្ណល្បែងផ្សងសំណាង និង/ឬអាជ្ញាបណ្ណសាខាល្បែងផ្សងសំណាង និង/ឬលិខិតអនុញ្ញាតប៉ុស្តិ៍សេវាល្បែងផ្សងសំណាង៖**

- ត្រូវអនុវត្តឱ្យបានត្រឹមត្រូវ តាមសៀវភៅបន្ទុកស្ដីពីលក្ខខណ្ឌនៃការផ្ដល់អាជ្ញាបណ្ណល្បែង-ផ្សងសំណាង
- ត្រូវធ្វើប្រតិបត្តិការអាជីវកម្មនៅទីតាំងដែលមានបញ្ជាក់នៅលើអាជ្ញាបណ្ណល្បែងផ្សងសំណាង ឬអាជ្ញាបណ្ណសាខាល្បែងផ្សងសំណាង ឬលិខិតអនុញ្ញាតប៉ុស្តិ៍សេវាល្បែងផ្សងសំណាង តែប៉ុណ្ណោះ



Address: No 6-8 Preah Norodom Blvd, Phnom Penh, Cambodia. Phone: (+855)23 902 090

- ត្រូវលើកស្លាកយីហោឱ្យបានត្រឹមត្រូវនៅគ្រប់ទីតាំងអាជីវកម្ម បន្ទាប់ពីទទួលបានអាជ្ញាបណ្ណល្បែងផ្សងសំណាង ឬអាជ្ញាបណ្ណសាខាល្បែងផ្សងសំណាង ឬលិខិតអនុញ្ញាតប៉ុស្តិ៍សេវាល្បែងផ្សងសំណាង
- ត្រូវដាក់តាំងបង្ហាញអាជ្ញាបណ្ណល្បែងផ្សងសំណាងច្បាប់ដើមនៅទីតាំងក្រុមហ៊ុន ឬអាជ្ញាបណ្ណសាខាល្បែងផ្សងសំណាងច្បាប់ដើម នៅគ្រប់ទីតាំងសាខាល្បែងផ្សងសំណាង ឬលិខិតអនុញ្ញាតប៉ុស្តិ៍សេវាល្បែងផ្សងសំណាងច្បាប់ដើម នៅគ្រប់ទីតាំងប៉ុស្តិ៍សេវាល្បែង-ផ្សងសំណាង
- ត្រូវដំណើរការតែប្រភេទល្បែង និងឧបករណ៍ល្បែងដែលមានការអនុញ្ញាតពី **គ.ល.ក.**
- ត្រូវដាក់តាំងវិញ្ញាបនបត្រចុះបញ្ជីប្រភេទនិងឧបករណ៍ល្បែងសម្រាប់ល្បែងផ្សងសំណាង និងឧបសម្ព័ន្ធនៃវិញ្ញាបនបត្រចុះបញ្ជីប្រភេទនិងឧបករណ៍ល្បែងសម្រាប់ល្បែងផ្សងសំណាងច្បាប់ដើម នៅទីតាំងក្រុមហ៊ុន និងច្បាប់ថតចម្លងបញ្ជាក់ត្រឹមត្រូវពីអគ្គលេខាធិការដ្ឋាននៃ **គ.ល.ក.** នៅទីតាំងសាខាល្បែងផ្សងសំណាង និង/ឬទីតាំងប៉ុស្តិ៍សេវាល្បែងផ្សងសំណាង
- ត្រូវត្រួតពិនិត្យ និងគ្រប់គ្រងប្រតិបត្តិការល្បែងផ្សងសំណាង ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម ជំពូកទី៥ ***"ការត្រួតពិនិត្យនិងការគ្រប់គ្រងប្រតិបត្តិករល្បែងពាណិជ្ជកម្មនិងភាគីពាក់ព័ន្ធ"*** ត្រង់មាត្រា៥៣ មាត្រា៥៤ មាត្រា៥៥ មាត្រា៥៦ និងមាត្រា៥៧។

ក្នុងករណីប្រតិបត្តិករដែលកាន់អាជ្ញាបណ្ណល្បែងផ្សងសំណាង ឬអាជ្ញាបណ្ណសាខាល្បែងផ្សង-សំណាង ឬលិខិតអនុញ្ញាតប៉ុស្តិ៍សេវាល្បែងផ្សងសំណាង មិនអនុវត្តតាមការណែនាំខាងលើនេះ ឬលួចលាក់បង្កប់ការលេងល្បែងដែលមិនមានការអនុញ្ញាតពី **គ.ល.ក.** ត្រូវចាត់ទុកថាបានប្រព្រឹត្តល្មើសទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម និងត្រូវប្រឈមនឹងការពិន័យអន្តរការណ៍អនុលោមតាមអនុក្រឹត្យលេខ ១០២ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ស្តីពីការពិន័យអន្តរការណ៍ចំពោះបទល្មើសទៅនឹងច្បាប់ស្តីពី ការគ្រប់គ្រងល្បែងពាណិជ្ជកម្ម ព្រមទាំងឈានដល់ការព្យួរ ឬការដកហូតអាជ្ញាបណ្ណល្បែងផ្សងសំណាង និង/ឬអាជ្ញាបណ្ណសាខាល្បែងផ្សងសំណាង និង/ឬលិខិតអនុញ្ញាតប៉ុស្តិ៍សេវាល្បែង-ផ្សងសំណាង និងត្រូវផ្តន្ទាទោសយ៉ាងតាមច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសងនៃព្រះរាជាណាចក្រកម្ពុជា។

**២. ចំពោះអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ៖**

- **អគ្គលេខាធិការដ្ឋាននៃ គ.ល.ក.** ត្រូវគ្រប់គ្រង តាមដាន និងត្រួតពិនិត្យជាប់ជាប្រចាំនូវរាល់សកម្មភាពអាជីវកម្មល្បែងផ្សងសំណាងនៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងចាត់វិធានការតាមផ្លូវច្បាប់ឱ្យបានទាន់ពេលចំពោះប្រតិបត្តិករល្បែងផ្សងសំណាងដែលអនុវត្តផ្ទុយពីសេច-ក្តីណែនាំនេះ
- **អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ពិសេសអគ្គស្នងការដ្ឋាននគរបាលជាតិ និងគណៈបញ្ជាការឯកភាពរាជធានី-ខេត្ត** ត្រូវផ្តល់ព័ត៌មាន និងចូលរួមសហការជាមួយ អគ្គលេខាធិការដ្ឋាននៃ **គ.ល.ក.** ដើម្បីចាត់វិធានការ និងទប់ស្កាត់រាល់ការធ្វើអាជីវកម្មល្បែងផ្សងសំណាងដែលមិនមានការអនុញ្ញាតពី **គ.ល.ក.** ក៏ដូចជា ដើម្បីចាត់វិធានការតាមបទប្បញ្ញត្តិជាធរមាន លើ

ប្រតិបត្តិករល្បែងផ្សងសំណាងដែលអនុវត្តផ្ទុយនឹងសេចក្តីណែនាំនេះ។ ទន្ទឹមនេះ អាជ្ញាធរ-មានសមត្ថកិច្ចពាក់ព័ន្ធ ក៏ត្រូវសហការគ្រប់គ្រង តាមដាន និងត្រួតពិនិត្យជាប់ជាប្រចាំនូវរាល់សកម្មភាពលួចលាក់បង្កប់ការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ និងចាត់វិធានការតាមផ្លូវច្បាប់ឱ្យបានទាន់ពេល ស្របតាមខ្លឹមសារនៃសេចក្តីណែនាំអន្តរក្រសួងលេខ ០២៨ សណន និងលេខ ០១២ សហវ ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការអនុវត្តវិធានការបង្ក្រាបល្បែងស៊ីសងខុសច្បាប់។

ទទួលបានសេចក្តីណែនាំនេះ អគ្គលេខាធិការ **គ.ល.ក.** អគ្គស្នងការនគរបាលជាតិ គណៈបញ្ជាការឯកភាពរាជធានី-ខេត្ត និងអាជ្ញាធរពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ព្រមទាំងប្រតិបត្តិករល្បែងផ្សងសំណាងទាំងអស់ត្រូវយកចិត្តទុកដាក់អនុវត្តតាមសេចក្តីណែនាំនេះ ដោយស្មារតីទទួលខុសត្រូវ និងឱ្យមានប្រសិទ្ធភាពខ្ពស់។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា
  "ដើម្បីជូនជ្រាប"
- ឯកសារ កាលប្បវត្តិ